# ធម្មកថា

## របស់ព្រះតេជព្រះគុណបណ្ឌិត ហុក-សាវណ្ណ អំពីអគតិធម៌ទាំងបួន

**Website: www.hoksavann.org**

ថ្ងៃទី១៤ វិច្ឆិកា ២០០៤

អគតិធម៌ប្រែថាធម៌លំអៀងមាន៤យ៉ាង គឺឆន្ទាគតិលំអៀងព្រោះស្រឡាញ់ ភោសាគតិលំអៀងព្រោះស្អប់ ភយាគតិលំអៀងព្រោះខ្លាច មោហាគតិលំអៀងព្រោះល្ងង់ ។ អគតិទាំង៤នេះ ជាអំពើអយុត្តិធម៌ ប្រែថាធម៌ពុំត្រឹមត្រូវ ជាគន្លងនៃអំពើបាប ។

ពាក្យថាឆន្ទាគតិលំអៀងព្រោះស្រឡាញ់ គឺសំរេចសេចក្តីអ្វីមួយដោយការកាន់ជើង បើចៅក្រមកាត់សេចក្តី សំរេចឲ្យអ្នកដែលខ្លួនកាន់ជើងនេះឈ្នះ ព្រោះហេតុតែសេចក្តីស្រឡាញ់ ទោះបីអ្នកនោះមានកំហុសក៏ដោយ ។ ទោសាគតិលំអៀងព្រោះស្អប់ បើទោះបីអ្នកដែលខ្លួនស្អប់នោះធ្វើត្រូវក៏ដោយ ក៏ឲ្យខុសឲ្យចាញ់ដែរ ព្រោះហេតុស្អប់ ។ ភយាគតិលំអៀងព្រោះភ័យខ្លាច គឺពុំហ៊ានសំរេចសេចក្តីឲ្យខុសដល់អ្នកដែលមានកំហុស ដែលជាអ្នកមានអំណាចបុណ្យស័ក្តិ មានទ្រព្យសម្បត្តិច្រើន ដោយខ្លាចអ្នកនោះធ្វើសេចក្តីអន្តរាយសងសឹកដល់ខ្លួនវិញ នេះជាលំអៀងព្រោះភ័យខ្លាច ។ មោហាគតិលំអៀងព្រោះល្ងង់ឬពុំដឹងការពិត គឺអ្នកមានវិជ្ជាតិច មានបញ្ញាទន់ខ្សោយ ឬជាអ្នកគ្មានសមត្ថភាព បានសំរេចបញ្ហាអ្វីមួយពុំត្រឹមត្រូវ ទៅតាមការពិតដោយភាពល្ងង់ខ្លៅរបស់ខ្លួន ។ អគតិធម៌ទាំង៤នេះ ជាធម៌អកុសល ជាអំពើបាប ដែលលោកអ្នកសប្បុរសតែងវៀរចាក ជាពិសេសចៅក្រមកាត់សេចក្តីក្នុងតុលាការ ត្រូវតែវៀរចាកកុំឲ្យកើតមាន ទើបការកាត់សេចក្តីមានយុត្តិធម៌ ។

ចំពោះតុលាការនៃប្រទេសដែលកាន់របបប្រជាធិបតេយ្យមានអំណាចឯករាជ្យដាច់ចេញពីអំណាចនីតិបញ្ញត្តិនិងនីតិប្រតិបត្តិ គឺរដ្ឋាភិបាល ។ បានសេចក្តីថា រដ្ឋាភិបាលមាននាយករដ្ឋមន្ត្រីឬរដ្ឋមន្ត្រីទី១ជាដើម ពុំអាចបញ្ជាទៅតុលាការឲ្យធ្វើតាមខ្លួនឡើយ ។ សូម្បីប្រធានាធិបតីឬប្រមុខរដ្ឋក៏ពុំអាចធ្វើដូច្នេះបានដែរ ផ្ទុយទៅវិញ បើរដ្ឋមន្ត្រីណាធ្វើខុសច្បាប់របស់រដ្ឋ តុលាការមានសិទ្ធិជំនុំជំរះកាត់ទោសរដ្ឋមន្ត្រីនោះបាន ដូចជាប្រជាពលរដ្ឋធម្មតាដែរ គឺមនុស្សគ្រប់រូប ទាំងប្រជាពលរដ្ឋ ទាំងអ្នករដ្ឋការ ត្រូវស្ថិតនៅក្រោមអំណាចច្បាប់រដ្ឋដូចគ្នា ។ បើអំណាចតុលាការពុំឯករាជ្យ ស្ថិតនៅក្រោមអំណាចរដ្ឋាភិបាល នោះតុលាការពុំអាចកាត់ទោសសមាជិករដ្ឋាភិបាលដែលប្រព្រឹត្តខុសបានឡើយ ។ ទាក់ទងនឹងអ្នកមានអំណាចរំលោភច្បាប់នេះ ដូចជាប៉ូលិសឬនគរបាល មាននាទីរក្សាសន្តិសុខជូនប្រជាពលរដ្ឋនៅក្នុងប្រទេស តែអាជ្ញាធរខ្មែរនេះ បែរទាត់ធាក់ប្រជាពលរដ្ឋដែលប្រព្រឹត្តខុសច្បាប់ចរាចរ ដែលតាមច្បាប់ត្រឹមតែផាកពិន័យ ឬហៅទៅទូន្មានប៉ុណ្ណោះ មិនត្រូវប្រើអំពើហឹង្សាបែបនេះឡើយ។ បើឃើញមនុស្សទាស់ទែងខ្វែងគំនិតគ្នា បំរុងប្រើអំពើហឹង្សា ប៉ូលិសឬនគរបាលត្រូវធ្វើអន្តរាគមន៍បំបែកចេញ មិនត្រូវប្រើអំពើហឹង្សាបែបណាមួយទៅលើប្រជាពលរដ្ឋឡើយ ។ ទោះបីឃើញអំពើឧក្រិដ្ឋជាក់ស្តែងប៉ូលិសឬនគរបាលអាចចាប់ឃុំ តែគ្មានសិទ្ធិធ្វើទណ្ឌកម្ម មានវាយដំជាដើមដល់អ្នកនោះឡើយ បើអ្នកនោះពុំបានតដៃទេ ។ ប៉ូលិសគ្មានសិទ្ធិកាត់ទោសមនុស្សដោយខ្លួនឯងឡើយ សិទ្ធិនេះនៅលើតុលាការ ។ អគតិធម៌ទាំង៤នេះ ជាធម៌ដែលអ្នកធំ អ្នកមានអំណាចត្រូវលះបង់ ហើយអនុវត្តតាមគតិធម៌ ជាពិសេសចៅក្រមកាត់សេចក្តី ។ ប្រទេសណាដែលមានចៅក្រមកាត់សេចក្តីពុំលំអៀងដោយអគតិទាំង៤នេះ ប្រទេសនោះមានដំណើរឆ្ពោះទៅរកនីតិរដ្ឋហើយ ។ អ្នករំលោភច្បាប់អាចថយចុះដោយសារចៅក្រមកាត់សេចក្តីប្រកបដោយគតិយុត្តិធម៌ផ្តន្ទាទោសតាមកំហុសដល់អ្នកដែលរំលោភច្បាប់ ។៚